ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៣-០១៣-១០៥ ប្រ.ក

# ប្រកាស
# ស្តីពី
# លក្ខណៈសម្គាល់នៃធនប័ត្រ ប្រភេទ ១០០០០០ រៀល គំរូថ្មី

អនុលោមតាមអនុក្រឹត្យលេខ ២១៥ អនក្រ.បក របស់រាជរដ្ឋាភិបាល ចុះថ្ងៃទី៣០ ខែ មេសា ឆ្នាំ ២០១៣ ស្តីពីការចេញផ្សាយធនប័ត្រ ប្រភេទ ១០០០០០ រៀល គំរូថ្មី ក្នុងព្រះរាជាណាចក្រកម្ពុជា ធនាគារជាតិនៃកម្ពុជាសូមប្រកាសផ្សាយជាសាធារណៈនូវលក្ខណៈសំគាល់នៃធនប័ត្រថ្មីនេះ មានដូចខាងក្រោម ៖

**ក- <u>លក្ខណៈទូទៅ</u> ៖**

- ទំហំធនប័ត្រ ៖ បណ្តោយ ១៧០ មម និងទទឹង ៧៥ មម
- ពណ៌ចម្បង គឺពណ៌បៃតង និងពណ៌ប្រផេះ

**ខ- <u>ផ្ទៃខាងមុខ</u> ៖**

- **ផ្នែកកណ្តាល** ខាងស្តាំត្រូវបានរំលេចឡើងនូវ ព្រះឆាយាល័ក្ខណ៍មើលពីមុខបញ្ឆិតចំហៀងខាងឆ្វេងនៃអតីតព្រះមហាក្សត្រ **ព្រះបរមរតនកោដ្ឋ** និង**សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ** ខាងឆ្វេងមានលេខ “ ១០០០០០ ” នៅពីលើគេ បន្ទាប់មកគឺជាហត្ថលេខារបស់ទេសាភិបាលនិងអគ្គបេឡា ព្រមទាំងរូបភាពព្រះសង្ហារនៃព្រះរាជាណាចក្រកម្ពុជា និងនៅខាងក្រោមមានលេខ-មាលាដែលបោះពុម្ពដោយទឹកខ្មៅពណ៌ខ្មៅ រូបចម្លាក់នាគក្បាល ៩ និងអក្សរ “ មួយសែនរៀល ” ព្រមទាំងអក្សរ “ អ្នកក្លែងក្រដាសប្រាក់នឹងត្រូវផ្តន្ទាទោសតាមច្បាប់ ” នៅគែមខាងក្រោមនោះ ។
- **ផ្នែកខាងស្តាំ** ជ្រុងលើមានអក្សរ “ ធនាគារជាតិនៃកម្ពុជា ” ព្រមទាំងលេខ-មាលាដែលត្រូវបានបោះពុម្ពដោយទឹកខ្មៅពណ៌ក្រហមនៅពីក្រោមនោះ និងជ្រុងខាងក្រោមមានលេខ “ ១០០០០០ ” និង “ 100000 ” នៅបន្ទាប់គ្នា ។
- **ផ្នែកខាងឆ្វេង** មានលេខ “ 100000 ” ព្រាលៗដែលត្រូវបានបោះពុម្ពតាមបន្ទាត់បញ្ឈរ ព្រមទាំងមាននិមិត្តសញ្ញាពិសេសសម្រាប់ជនពិការភ្នែកនៅពីក្រោមនោះ និងនៅកៀនខាងឆ្វេងមានបន្ទះ Hologram ទំហំ ១០ ស.ម កាត់ទទឹងក្រដាសប្រាក់ពីលើដល់ក្រោម ។

**គ- <u>ផ្ទៃខាងខ្នង</u> ៖**

- **ផ្នែកកណ្តាល** ត្រូវបានរំលេចឡើងនូវព្រះឆាយាល័ក្ខណ៍នៃអតីតព្រះមហាក្សត្រ **ព្រះបរមរតនកោដ្ឋ** និង**សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ** ព្រមទាំង**ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា និងមានអក្សរ “ មួយសែនរៀល ” នៅពីក្រោយនោះ ។

ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

- **ផ្នែកខាងស្តាំ** មានរូបភាពស្តេចគ្រុឌឈរសម្តែងឫទ្ធិ ដែលយកគំរូតាមរូបចម្លាក់ថ្ម នៅប្រាសាទព្រះខ័នក្នុងខេត្តសៀមរាប និងមានលេខ “ ១០០០០០ ” នៅពីក្រោមនោះ ព្រមទាំងលេខ “ 100000 ” ដែលត្រូវបានបោះពុម្ពតាមបន្ទាត់បញ្ឈរ នៅកៀនខាងស្តាំ ។

- **ផ្នែកខាងឆ្វេង** ខាងលើមានអក្សរ “ ធនាគារជាតិនៃកម្ពុជា” និង “ NATIONAL BANK OF CAMBODIA ” នៅបន្ទាប់គ្នា ព្រមទាំងលេខ“ 2012 ” នៅពីក្រោមនោះ និងនៅជ្រុងខាងក្រោមមានលេខ “ ១០០០០០ ” ។

ចាប់ពីថ្ងៃចេញប្រកាសនេះតទៅ ធនប័ត្រប្រភេទ ១០០០០០ រៀល គំរូថ្មី ត្រូវបានដាក់ឲ្យធ្វើចរាចរទន្ទឹមគ្នាជាមួយនឹងធនប័ត្រជាតិប្រភេទផ្សេងៗទៀត ដែលត្រូវបានចេញផ្សាយកន្លងមក ។ សាធារណជនគ្រប់រូបត្រូវពិនិត្យ-សម្គាល់ធនប័ត្រថ្មីនេះ ឲ្យបានច្បាស់លាស់ ដើម្បីជៀសវាងការភាន់ច្រឡំ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០១៣

**ទេសាភិបាល**

ជា.ចាន់តូ